**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
លេខ ០០៧៤ សនក.ប្រកអ

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការដំឡើងកម្រិត និងការបង្កើតអង្គភាពសុខាភិបាល

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៩៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត



អាសយដ្ឋាន៖ ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីម៉ែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia

- បានឃើញប្រកាសអន្តរក្រសួងលេខ ១៥២ សនក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានី ខេត្ត
- យោងលិខិតលេខ ៨៩៣/២៤ មស.ន.នក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការឯកភាពក្នុងការដំឡើង និងបង្កើតអង្គភាពសុខាភិបាល ចំនួន ២១ សម្រាប់ឆ្នាំ២០២៣
- យោងលិខិតលេខ ៧៩៨១ សហវ.ល.ស.អ.ថ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការឯកភាពក្នុងការដំឡើងកម្រិត និងបង្កើតអង្គភាពសុខាភិបាលថ្មី ចំនួន ២១កន្លែង សម្រាប់ឆ្នាំ២០២៣
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតការិយាល័យសុខាភិបាលស្រុកប្រតិបត្តិសំបូរ ស្ថិតនៅភូមិសំបូរ ឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ ក្រោមការគ្រប់គ្រងរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តក្រចេះ។

**ប្រការ២ .-**

ត្រូវបានបង្កើតមន្ទីរពេទ្យបង្អែកមានជ័យ កម្រិត១ (CPA1) ស្ថិតនៅភូមិព្រែកតាឡុង៣ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបាសាក់ នៃមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ។

**ប្រការ៣ .-**

ត្រូវបានដំឡើងពីមណ្ឌលសុខភាពកូនមុំ ទៅជាមន្ទីរពេទ្យបង្អែកកូនមុំ កម្រិត១ (CPA1) ស្ថិតនៅភូមិ៣ ឃុំត្រពាំងច្រេស ស្រុកកូនមុំ ខេត្តរតនគិរី ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបានលុង នៃមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តរតនគិរី។

**ប្រការ៤ .-**

ត្រូវបានដំឡើងពីប៉ុស្តិ៍សុខភាពកោះកាពិ ទៅជាមណ្ឌលសុខភាពកោះកាពិ ស្ថិតនៅភូមិកោះកាពិ១ ឃុំកោះកាពិ ស្រុកកោះកុង ខេត្តកោះកុង ស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្មាច់មានជ័យ នៃមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកោះកុង។

**ប្រការ៥ .-**

ត្រូវបានបង្កើតមណ្ឌលសុខភាពថ្មី ចំនួន ៨កន្លែង ស្ថិតក្រោមឱវាទមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត ចំនួន៤ ដូចខាងក្រោម៖

**ក- រដ្ឋបាលខេត្តកោះកុង**

១- មណ្ឌលសុខភាពយន្តមីនជ្រោយស្វាយ ស្ថិតនៅភូមិភ្នំស្រឡៅ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ស្ថិតក្រោមការគ្រប់គ្រងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្រែអំបិល។

**ខ- រដ្ឋបាលខេត្តកំពង់ស្ពឺ**

១- មណ្ឌលសុខភាពដំណាក់ដំរី ស្ថិតនៅភូមិទី៣ ឃុំយាយម៉ៅពេជ្រនិល ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

ស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិភ្នំស្រួច

២- មណ្ឌលសុខភាពអូរគគី ស្ថិតនៅភូមិអូរគគី ឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិកំពង់ស្ពឺ

៣- មណ្ឌលសុខភាពរលាក់កងជើង ស្ថិតនៅភូមិគ្រៀលពង ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិកំពង់ស្ពឺ

៤- មណ្ឌលសុខភាពណូនរ៉ែន ជំពូព្រឹក្ស ស្ថិតនៅភូមិក្រាំងតាសោម ឃុំជំពូព្រឹក្ស ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ ស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិកំពង់ស្ពឺ។

**គ- រដ្ឋបាលខេត្តកំពង់ចាម**

១- មណ្ឌលសុខភាពជាលា ស្ថិតនៅភូមិជាលា ឃុំជាលា ស្រុកបាធាយ ខេត្តកំពង់ចាម ស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបាធាយ

២- មណ្ឌលសុខភាពមេព្រីង ស្ថិតនៅភូមិមេព្រីង ឃុំមេព្រីង ស្រុកបាធាយ ខេត្តកំពង់ចាម ស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបាធាយ។

**ឃ- រដ្ឋបាលខេត្តត្បូងឃ្មុំ**

១- មណ្ឌលសុខភាពគោកស្រុក ស្ថិតនៅភូមិស៊ាងឃ្វាង ឃុំគោកស្រុក ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិតំបែរ។

**ប្រការ៦ ._**

ត្រូវបានបង្កើតប៉ុស្តិ៍សុខភាពថ្មី ចំនួន ៩កន្លែង ស្ថិតក្រោមឱវាទមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត ចំនួន៦ ដូចខាងក្រោម៖

**ក- រដ្ឋបាលខេត្តកោះកុង**

១- ប៉ុស្តិ៍សុខភាពកណ្តោល ស្ថិតនៅភូមិកណ្តោល ឃុំកណ្តោល ស្រុកបូទុមសាគរ ខេត្តកោះកុង ស្ថិតក្រោមការគ្រប់គ្រងរបស់មណ្ឌលសុខភាពអណ្តូងទឹក នៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្រែអំបិល

២- ប៉ុស្តិ៍សុខភាពភ្ញីមាស ស្ថិតនៅភូមិភ្ញីមាស ឃុំភ្ញីមាស ស្រុកគិរីសាគរ ខេត្តកោះកុង ស្ថិតក្រោមការគ្រប់គ្រងរបស់មណ្ឌលសុខភាពគិរីសាគរ នៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្មាច់មានជ័យ

៣- ប៉ុស្តិ៍សុខភាពជ្រោយប្រស់ ស្ថិតនៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង ស្ថិតក្រោមការគ្រប់គ្រងរបស់មណ្ឌលសុខភាពត្រពាំងរូង នៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្មាច់មានជ័យ

៤- ប៉ុស្តិ៍សុខភាពទួលគគីរ ស្ថិតនៅភូមិតាចាត ឃុំទួលគគីរ ស្រុកមណ្ឌលសីមា ខេត្តកោះកុង ស្ថិតក្រោមការគ្រប់គ្រងរបស់មណ្ឌលសុខភាពប៉ាក់ខ្លង នៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្មាច់មានជ័យ។

**ខ- រដ្ឋបាលខេត្តព្រះសីហនុ**

១- ប៉ុស្តិ៍សុខភាពកោះរ៉ុងសន្លឹម ស្ថិតនៅភូមិកោះរ៉ុងសន្លឹម សង្កាត់កោះរ៉ុងសន្លឹម ក្រុងកោះរ៉ុង ខេត្តព្រះសីហនុ ស្ថិតក្រោមការគ្រប់គ្រងរបស់មណ្ឌលសុខភាពកោះរ៉ុង នៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រះសីហនុ។

**គ- រដ្ឋបាលខេត្តកំពង់ចាម**

១- ប៉ុស្តិ៍សុខភាពកោះអណ្តែត និង KIT MPA ស្ថិតនៅភូមិក្បាលកោះ ឃុំកោះអណ្តែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ស្ថិតក្រោមការគ្រប់គ្រងរបស់មណ្ឌលសុខភាពព្រែករំដេង នៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្រីសន្ធរ។

**ឃ- រដ្ឋបាលខេត្តកំពង់ធំ**

១- ប៉ុស្តិ៍សុខភាពដូង ស្ថិតនៅភូមិតេជោអភិវឌ្ឍន៍ និងគ្រប់សុខសែនជ័យ ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ស្ថិតក្រោមការគ្រប់គ្រងរបស់មណ្ឌលសុខភាពដូង នៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្ទោង។

**ង- រដ្ឋបាលខេត្តកំពត**

១- ប៉ុស្តិ៍សុខភាពបឹងទូក ស្ថិតនៅភូមិទទឹងថ្ងៃ សង្កាត់បឹងទូក ក្រុងបូកគោ ខេត្តកំពត ស្ថិតក្រោមការគ្រប់គ្រងរបស់មណ្ឌលសុខភាពកោះតូច នៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិកំពត។

**ច- រដ្ឋបាលខេត្តមណ្ឌលគិរី**

១- ប៉ុស្តិ៍សុខភាពឡៅកា ស្ថិតនៅភូមិឡៅកា សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ស្ថិតក្រោមការគ្រប់គ្រងរបស់មណ្ឌលសុខភាពសែនមនោរម្យ នៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិសែនមនោរម្យ។

**ប្រការ៧.-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល ព្រមទាំងក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត និងប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**អភិសន្តិបណ្ឌិត ស សុខា** | **សាស្ត្រាចារ្យ ឈាង រ៉ា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលរាជធានី ខេត្ត ពាក់ព័ន្ធ
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ